Disability Rights California

*California's protection & advocacy system*
*ទូរស័ព្ទហៅមិនអស់ប្រាក់* (800) 776-5746

# ការទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយតាមរយៈសាលារៀនរបស់កូនអ្នក

*ខែកញ្ញា ឆ្នាំ2015 ឯកសារបោះពុម្ពផ្សាយលេខ* **5577.06 - Cambodian**

## 1. តើអ្វីជាឧបករណ៍បច្ចេកវិជ្ជាជំនួយនៅក្នុងការអប់រំពិសេស (assistive technology)?

ឧបករណ៍បច្ចេកវិជ្ជាជំនួយ ត្រូវបានកំណត់និយមន័យពីរដងដោយច្បាប់ការអប់រំពិសេសរបស់រដ្ឋាភិបាលសហព័ន្ធ ។ និយមន័យចំពោះពាក្យនេះ ត្រូវបានកំណត់ជាពិសេសដោយ (IDEA, Individuals with Disabilities Education Act)

ថាជា "របស់ ចំណែកនៃឧបករណ៍ ឬប្រព័ន្ធផលិតផល មិនថាជាផលិតផលដែលមានលក់ជាទូទៅ ផលិតផលដែលត្រូវបានកែសម្រួល ឬកែប្រែឲ្យស្របទៅតាមលក្ខណៈបុគ្គល ដែលត្រូវបានគេប្រើដើម្បីបង្កើន ថែរក្សា ឬជម្រុញសមត្ថភាពការធ្វើចលនារាងកាយរបស់កុមារពិការ" ។ 20 ក្រមសហរដ្ឋអាមេរិក (U.S.C., United States Code) វគ្គទី1401(1) ។ និយត្តកម្មការឆ្លើយតបគឺសំដៅលើបច្ចេកវិជ្ជាជំនួយដែលជាឧបករណ៍ ឬសេវាកម្មណាមួយដែលកូនរបស់អ្នកត្រូវការ ដើម្បីជួយឲ្យគេអាចទទួលបានផលប្រយោជន៍ពីសេវាកម្មការអប់រំពិសេសរបស់គេ ឬសេវាកម្មដែលពាក់ព័ន្ធ ឬអាចជួយឲ្យកូនអ្នកទទួលបានការអប់រំរបស់ពួកគេនៅក្នុងបរិស្ថានដែលមានការកំហិតតិចតួចបំផុត ។ 34 ក្រមនិយត្តកម្មសហព័ន្ធ (C.F.R., Code of Federal Regulations) វគ្គទី 300.110 និងវគ្គទី 300.114 ។

## 2. តើនរណាមានសិទ្ធិទទួលបានសេវាកម្មផ្តល់ឧបករណ៍បច្ចេកវិជ្ជាជំនួយ?

ក្មេងពិការដែលត្រូវការសេវាកម្មអប់រំពិសេសដើម្បីជួយឲ្យរូបគេទទួលបានផលប្រយោជន៍ពីការអប់រំ គឺជាអ្នកដែលមានសិទ្ធិទទួលបានសេវាកម្មអប់រំពិសេស

និងសេវាកម្មនានាដែលពាក់ព័ន្ធ ។ សេវាកម្មនានាដែលពាក់ព័ន្ធ មានរួមបញ្ចូលនូវឧបករណ៍បច្ចេកវិជ្ជាជំនួយ ។ សម្រាប់ព័ត៌មានលំអិត អំពីអ្វីដែលចាត់ទុកថាជាសេវាកម្មបច្ចេកវិជ្ជាជំនួយ សូមអានឯកសារ បោះពុម្ពផ្សាយរបស់អង្គការ Disability Rights California ស្ដីអំពី *សិទ្ធិទទួលបានការអប់រំពិសេស និងការទទួលខុសត្រូវ (SERR, Special Education Rights and Responsibilities)* សៀវភៅក្បួនខ្នាត ក្នុងជំពូកទី 5 *ព័ត៌មានអំពីសេវាកម្មនានាដែលពាក់ព័ន្ធ (Information on Related Services)* ដែលមាននៅឯ ៖ http://www.disabilityrightsca.org/pubs/504001.pdf។

### 3. តើខ្ញុំអាចស្នើសុំឧបករណ៍បច្ចេកវិជ្ជាជំនួយដោយរបៀបណា?

អ្នកអាចស្នើសុំឧបករណ៍បច្ចេកវិជ្ជាជំនួយតាមរយៈផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល (IEP, Individualized Education Plan) ឬស្នើសុំឲ្យមានការវាយតម្លៃ អំពីតម្រូវការឧបករណ៍បច្ចេកវិជ្ជាជំនួយ ។ សម្រាប់ព័ត៌មានលំអិតបន្ថែម អំពីការវាយតម្លៃ សូមអានឯកសារបោះពុម្ពផ្សាយរបស់អង្គការ Disability Rights California ស្ដីអំពី *សិទ្ធិទទួលបានការអប់រំពិសេស និងការទទួលខុសត្រូវ (SERR)* សៀវភៅក្បួនខ្នាត ក្នុងជំពូកទី 2 *ព័ត៌មានអំពីការវាយតម្លៃ/ការប៉ាន់ប្រមាណ (Information on Evaluations/Assessments)* ដែលមាននៅឯ ៖ http://www.disabilityrightsca.org/pubs/504001.pdf ។

### 4. តើខ្ញុំអាចឲ្យគេដាក់បញ្ចូលឧបករណ៍បច្ចេកវិជ្ជាជំនួយ ក្នុងផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល របស់កូនខ្ញុំបានដោយរបៀបណា?

កូនរបស់អ្នកត្រូវតែត្រូវការឧបករណ៍បច្ចេកវិជ្ជាជំនួយ ដើម្បីជួយឲ្យគេអាចទទួលបានផលប្រយោជន៍ពីការអប់រំពិសេស ។ ឧបករណ៍បច្ចេកវិជ្ជាជំនួយ អាចជាផ្នែកមួយនៃគោលបំណង និងទិសដៅរបស់កូនអ្នកសម្រាប់ ការអប់រំពិសេស ។ 34 C.F.R. វគ្គទី 300.39 ។ ឧទាហរណ៍ កូនរបស់អ្នកអាចត្រូវការឧបករណ៍ទំនាក់ទំនង ដើម្បីជួយគេក្នុងការឆ្លើយសំណួរ និងនិយាយជាមួយគ្រូ ឬមិត្តរបស់គេ ។ ឧបករណ៍បច្ចេកវិជ្ជាជំនួយអាចជាផ្នែកមួយនៃសេវាកម្មដែលពាក់ព័ន្ធ ។ 34 C.F.R. វគ្គទី300.34 ។ វាអាចជាសេវាកម្មដែលពាក់ព័ន្ធ ឬជួយឲ្យកូនអ្នកអាចទទួលបានផលប្រយោជន៍ពីសេវាកម្មដែលពាក់ព័ន្ធ ។ ឧបករណ៍បច្ចេកវិជ្ជាជំនួយ អាចជាឧបករណ៍ ឬសេវាកម្មជំនួយបន្ថែម ដែលជួយឲ្យកូនអ្នកអាចទទួលការអប់រំក្នុងបរិស្ថានដែលមានកំហិតតិចបំផុត ។ 34 C.F.R. វគ្គទី 300.42 និងវគ្គទី 300.114(a)(2) ។ សមាជិកក្រុមផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល គួរពិចារណាចំពោះឧបករណ៍

បច្ចេកវិជ្ជាជំនួយ ដែលជួយឲ្យកូនអ្នកអាចរៀនបាននៅក្នុងថ្នាក់រៀនធម្មតា មុនពេលពិចារណាឲ្យគេរៀនក្នុងបរិស្ថានដែលមានកំហិតខ្លាំង ។

សមាជិកក្រុមផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល ត្រូវបានតម្រូវឲ្យពិចារណា អំពីតម្រូវការរបស់កុមារចំពោះឧបករណ៍ និង/ឬសេវាកម្មបច្ចេកវិជ្ជាជំនួយ នៅពេលរៀបចំផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល ។ 20 U.S.C. វគ្គទី1414(d)(3)(B)(v) ។ បើកូនរបស់អ្នកជាជនពិការភ្នែកដែលត្រូវការពុម្ពអក្សរសម្រាប់មនុស្សងងឹតភ្នែក ពេលនោះសមាជិកក្រុមផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល ត្រូវរៀបចំឲ្យមានការ បង្រៀនពុម្ពអក្សរសម្រាប់មនុស្សពិការភ្នែក និងការប្រើប្រាស់វា ។ ករណីលើកលែងមានតែមួយគឺ នៅពេលដែលសមាជិកក្រុមផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល កំណត់ថាការប្រើប្រាស់ពុម្ពអក្សរសម្រាប់មនុស្សពិការភ្នែក គឺវាមិនមានភាពសមរម្យសម្រាប់កូនអ្នកឡើយ ក្រោយពេលពួកគេធ្វើការវាយតម្លៃពីតម្រូវការបច្ចុប្បន្ន និងអនាគតរបស់កូនអ្នក ។ 20 U.S.C. វគ្គទី 1414(3)(B)(iii) ។

5. **តើនរណាជាម្ចាស់កម្មសិទ្ធិចំពោះ ឧបករណ៍បច្ចេកវិជ្ជាជំនួយដែលសាលាទិញឲ្យសិស្ស?**

ឧបករណ៍ដែលសាលាជាអ្នកទិញ គឺជាកម្មសិទ្ធិរបស់សាលា ។ ឧបករណ៍នេះត្រូវទុកនៅសាលា បើកូនរបស់អ្នកប្តូរទៅកាន់មណ្ឌលសិក្សាផ្សេង ។

6. **តើកូនរបស់ខ្ញុំអាចយកឧបករណ៍បច្ចេកវិជ្ជាជំនួយដែលសាលាទិញឲ្យប្រើ មកផ្ទះបានទេ?**

អាចយកទៅបាន ។ បើកូនរបស់អ្នកត្រូវការ ឧបករណ៍បច្ចេកវិជ្ជាជំនួយសម្រាប់ប្រើនៅផ្ទះ ដើម្បីជួយឲ្យមានភាពរីកចម្រើនឈានទៅរកគោលបំណងផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គលរបស់គេ ។ មណ្ឌលសិក្សាស្រុក មិនអាចកំណត់ ឲ្យកូនអ្នកអាចប្រើឧបករណ៍ជំនួយតែនៅសាលាឡើយ ប្រសិនបើសិស្សរូបនេះ ត្រូវការប្រើវានៅផ្ទះ ដើម្បីជួយឲ្យគេអាចទទួលបាន ការអប់រំសាធារណៈដែលមានភាពសមរម្យ និងមិនបាច់បង់ថ្លៃ (FAPE, free, appropriate, public education) ។ បើឧបករណ៍នោះវាមានភាពចាំបាច់ ចំពោះកូនអ្នក ក្នុងការធ្វើកិច្ចការសាលា ឬដើម្បីអនុវត្តបំណិននៅខាងក្រៅសាលា ឧបករណ៍នេះត្រូវតែដាក់បញ្ចូលក្នុងផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល របស់គេ ។

## 7. តើមណ្ឌលសិក្សាស្រុកអាចបង្ខំខ្ញុំឲ្យចុះហត្ថលេខាទទួលខុសត្រូវចំពោះការខូចខាត ហើយបង្ខំខ្ញុំឲ្យចេញថ្លៃសងឧបករណ៍ដែលខូចខាតដែរឬទេ?

មណ្ឌលសិក្សាស្រុកអាចតម្រូវឲ្យឪពុកម្ដាយសិស្សចុះហត្ថលេខាទទួលខុសត្រូវមានកម្រិត ដែលតម្រូវឲ្យពួកគេសងចំពោះការបាត់បង់ ឬការខូចខាតឧបករណ៍ តែការធ្វើបែបនេះសម្រាប់តែហេតុការណ៍ជាក់លាក់មួយចំនួនតែប៉ុណ្ណោះ ។ មណ្ឌលសិក្សាស្រុកមិនអាចបង្ខំឲ្យឪពុកម្ដាយសិស្សត្រូវសងមកវិញនូវបច្ចេកវិជ្ជាដែលបានខូចខាត ឬបាត់បង់ដែលបណ្ដាលមកពីលទ្ធផលនៃពិការភាពរបស់សិស្សឡើយ ហើយមណ្ឌលសិក្សាស្រុកមិនត្រូវស្នើឲ្យមានការទទួលខុសត្រូវដែលតម្រូវឲ្យឪពុកម្ដាយសិស្សត្រូវសងវិញនូវបច្ចេកវិជ្ជាដែលខូចខាត ឬបាត់បង់ចំពោះការប្រើប្រាស់តាមបែបធម្មតាឡើយ ។ ឧទាហរណ៍ ប្រសិនបើផ្នែកចាស់មួយរបស់ឧបករណ៍ដែលសិស្សបានប្រើដោយត្រឹមត្រូវ ហើយអេក្រង់របស់វាគាំង មិនដំណើរការ មណ្ឌលសិក្សាស្រុកមិនអាចស្នើសុំឲ្យឪពុកម្ដាយសិស្ស ទិញឧបករណ៍ថ្មីមកជំនួសឡើយ ។ លើសពីនេះ ក្នុងស្ថានភាពដែលឧបករណ៍បច្ចេកវិជ្ជាជំនួយត្រូវបានគេលួចបាត់ ដោយមិនមែនជាកំហុសរបស់សិស្ស ឬឪពុកម្ដាយ គឺមានន័យថា ឪពុកម្ដាយសិស្សមិនមែនជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់នេះឡើយ ។ ប្រសិនបើពិការភាពរបស់សិស្ស ជាមូលហេតុនាំឲ្យសិស្សភ្លេចភ្លាំង មណ្ឌលសិក្សាស្រុកមិនត្រូវរំពឹងឲ្យឪពុកម្ដាយសិស្សចេញថ្លៃឧបករណ៍ដែលបាត់បង់ឡើយ តែមណ្ឌលសិក្សាស្រុកត្រូវបង្កើតផែនការពីដំបូង ដើម្បីធានាក្នុងការមិនធ្វើឲ្យឧបករណ៍នោះត្រូវបាត់បង់ពេលសិស្សប្រើ ។

បើមណ្ឌលសិក្សស្រុកស្នើសុំឲ្យមានការទទួលខុសត្រូវលើឧបករណ៍ជំនួយ ឪពុកម្ដាយសិស្សត្រូវចរចាអំពីលក្ខ័ណ្ឌ ដើម្បីធានាបានថា ឪពុកម្ដាយសិស្សមិនមែនជាអ្នក ទទួលខុសត្រូវចំពោះការខូចខាតឧបករណ៍ដែលអាចមាន ។

ឪពុកម្ដាយសិស្សអាចជាអ្នកទទួលខុសត្រូវចំពោះការខូចខាត ឬការបាត់បង់ឧបករណ៍ ដែលកើតឡើងនៅពេលដែលឧបករណ៍នោះត្រូវខូចខាត ឬបាត់បង់ ក្នុងពេលសិស្សប្រើវាខុសពីអ្វីដែលគេតម្រូវឲ្យប្រើ និងប្រើខុសប្រកតី ។ ឧទាហរណ៍ បើសិស្សមានម៉ាស៊ីនកុំព្យូទ័រ ហើយទាញយកកម្មវិធី ឬអាប់ (app) ណាមួយដែលមិនពាក់ព័ន្ធជាមួយនឹងសាលា ហើយកម្មវិធី ឬអាប់នោះមានមេរោគ គឺមានន័យថា វាជាការប្រើប្រាស់ឧបករណ៍ដោយមិនសមរម្យ ហើយអាចតម្រូវឲ្យឪពុកម្ដាយសិស្សជាអ្នកចេញថ្លៃការខាតបង់ ។ លើសពីនេះ បើសិស្សអនុញ្ញាតឲ្យអ្នកដទៃ (រួមទាំងឪពុកម្ដាយ) ប្រើឧបករណ៍នោះ ហើយអ្នកនោះបានធ្វើឲ្យឧបករណ៍ខូច គឺឪពុកម្ដាយ ត្រូវចេញថ្លៃខូចខាតដល់មណ្ឌលសិក្សាស្រុក ។

**8. តើមណ្ឌលសិក្សាស្រុកអាចឲ្យខ្ញុំប្រើជំនួយកម្មវិធី Medi-Cal ឬការធានារ៉ាប់រងឯកជន ដើម្បីទិញឧបករណ៍នេះបានដែរឬទេ?**

ការប្រើថវិកាពីប្រភពផ្សេង ដូចជាថវិកាពីកម្មវិធី Medi-Cal ឬការធានារ៉ាប់រងឯកជន គឺជាការសម្រេចចិត្តរបស់អ្នក ហើយត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត ។ មណ្ឌលសិក្សាស្រុក មិនអាចបង្ខំអ្នកឲ្យរងទុកចំពោះ ការខាតបង់ថវិកាឡើយ ។ ការខាតបង់ថវិកា អាចរួមបញ្ចូលនូវការកាត់បន្ថយបរិមាណអត្ថប្រយោជន៍ពីការធានារ៉ាប់រងអាយុជីវិត បង្កើនថ្លៃបុព្វលាភរ៉ាប់ររង លុបចោលការធានារ៉ាប់រងចំណាយថវិកាដែលត្រូវចេញពីហោប៉ៅខ្លួន និងការកំណត់ចំពោះបរិមាណទឹកប្រាក់ដែលអ្នកអាចទារសំណងពីធានារ៉ាប់រង ។ បើទោះបីជាអ្នកស្ម័គ្រចិត្តប្រើថវិកាពីប្រភពផ្សេងក៏ដោយ ក៏មណ្ឌលសិក្សាស្រុកត្រូវមានកាតព្វកិច្ចក្នុងការផ្តល់សេវាកម្មទាំងអស់ដែលមានសរសេរនៅក្នុងផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គលដែរ។ ប្រសិនបើថវិកាពីប្រភពផ្សេងមិនអាចចេញការចំណាយថ្លៃឧបករណ៍បានទាំងស្រុងទេ សាលាត្រូវជួយចេញថ្លៃជាចំណែកទាំងអស់ដែលនៅសល់ ។

**9. តើមណ្ឌលសិក្សាស្រុក មានផ្តល់ការបណ្តុះបណ្តាលពីរបៀបប្រើឧបករណ៍បច្ចេកវិជ្ជាជំនួយដែរឬទេ?**

អាចផ្តល់ជូនបាន ។ មណ្ឌលសិក្សាស្រុកត្រូវផ្តល់ការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ដល់កូនអ្នក រូបអ្នក សមាជិកដទៃក្នុងគ្រួសារ និងបុគ្គលិកសាលា ដើម្បីធានាបានថាអ្នកទាំងអស់ចេះប្រើឧបករណ៍នោះបានសមរម្យ ។ មណ្ឌលសិក្សាស្រុកក៏ជាអ្នកទទួលខុសត្រូវក្នុងការចេញថ្លៃចំណាយលើការបណ្តុះបណ្តាលនេះដែរ ។ 20 U.S.C. វគ្គទី1401(2)(E) ។

**10. តើនរណាជាអ្នកទទួលខុសត្រូវក្នុងការជួសជុល និងថែរក្សាឧបករណ៍បច្ចេកវិជ្ជាជំនួយ?**

មណ្ឌលសិក្សាស្រុកជាអ្នកទទួលខុសត្រូវចំពោះការជួសជុល និងថែទាំឧបករណ៍ដែលខ្លួនជាអ្នក ទិញ ។ សមាជិកក្រុម IEP ត្រូវពិភាក្សាគ្នាអំពីការបណ្តុះបណ្តាល ការជួសជុល និងការថែទាំឧបករណ៍ជាមួយនឹងមណ្ឌលសិក្សាស្រុក ។ គ្រប់គ្នាត្រូវយល់ស្របចំពោះការរៀបចំ នៅមុនពេល IEP ។ វាគឺជាការទទួលខុសត្រូវរបស់មណ្ឌលសិក្សាស្រុក ក្នុងការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយធានារ៉ាប់រងទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីកំណត់ឲ្យឃើញថា មានការធានារ៉ាប់រងចំពោះការបាត់បង់ និងការខូចខាតឧបករណ៍នៅសាលារៀន និងនៅផ្ទះសិស្សដែរឬទេ ។

**11. តើមណ្ឌលសិក្សាស្រុក អាចប្រើតម្លៃជាកត្តាក្នុងការកំណត់ថាតើកូនរបស់ខ្ញុំអាចទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយដែរឬទេ?**

អាច។ តែគេធ្វើបែបនោះតែក្នុងករណីដែលថា ឧបករណ៍ដែលមានតម្លៃទាបជាងក៏អាចយកមកប្រើបានដែរ ។ តម្លៃមិនអាចយកមកធ្វើជាកត្តាកំណត់បានទេ ប្រសិនបើឧបករណ៍ដែលមានតម្លៃទាប មិនអាចជួយកូនអ្នកបានក្នុងការទទួលប្រយោជន៍ពី FAPE ។

**12. តើមណ្ឌលសិក្សាស្រុក អាចតម្រូវឲ្យកូនរបស់ខ្ញុំយកឧបករណ៍បច្ចេកវិជ្ជាជំនួយដែលខ្ញុំបានទិញដោយថវិកាខ្លួនឯង ទៅសាលាដែរឬទេ?**

សាលាមិនអាចបង្ខំអ្នកឲ្យកូនយកឧបករណ៍កម្មសិទ្ធិឯកជនទៅប្រើនៅសាលាបានទេ ។ សាលារៀនរបស់កូនអ្នក ត្រូវផ្តល់ជូននូវឧបករណ៍ដល់កូនអ្នក ដែលសមាជិកក្រុម IEP ប្រាប់ថា ជាអ្វីដែលកូនអ្នកត្រូវការ ។ 34 C.F.R. វគ្គទី 300.6(c) ។

**13. តើត្រូវធ្វើដូចម្តេច ប្រសិនបើមណ្ឌលសិក្សាស្រុក បដិសេធមិនព្រមផ្តល់ឧបករណ៍បច្ចេកវិជ្ជាជំនួយ ឬប្រភេទបច្ចេកវិជ្ជាជំនួយតាមការស្នើសុំរបស់ខ្ញុំទេនោះ?**

ដំបូង អ្នកអាចស្នើសុំការប្រជុំក្រុម IEP ដើម្បីពិភាក្សាគ្នាអំពីបញ្ហាដែលបានកើតឡើង និងរួមគ្នាស្វែងរកដំណោះស្រាយក្រៅផ្លូវការ ។ ប្រសិនបើឧបករណ៍បច្ចេកវិជ្ជាជំនួយនោះ ត្រូវបានយល់ព្រមគ្នានៅក្នុង IEP ហើយមណ្ឌលសិក្សាស្រុកមិនព្រមធ្វើតាម អ្នកមានសិទ្ធិប្តឹងមណ្ឌលសិក្សាស្រុកពីការមិនព្រមធ្វើតាមផែនការ ។ ប្រសិនបើអ្នកមិនយល់ស្របចំពោះ IEP ដែលបានស្នើឡើង អ្នកអាចដាក់ពាក្យប្តឹងជំទាស់ ដើម្បីស្នើសុំឲ្យមានសវនាការ ។ សម្រាប់ព័ត៌មានលំអិតបន្ថែម ស្តីអំពីការប្តឹង សូមអានឯកសារបោះពុម្ពផ្សាយរបស់អង្គការ Disability Rights California ស្តីអំពី *សិទ្ធិទទួលបានការអប់រំពិសេស និងការទទួលខុសត្រូវ (SERR)* សៀវភៅក្បួនខ្នាតត្រង់ជំពូកទី 6 *ព័ត៌មានស្តីអំពី នីតិវិធីចំពោះបណ្តឹងជំទាស់/ការមិនអនុវត្តតាមផែនការ (Information on Due Process/Compliance Procedures)* តាមរយៈ ៖ http://www.disabilityrightsca.org/pubs/504001.pdf ។

### 14. ប្រសិនបើ កូនរបស់ខ្ញុំមិនមានលក្ខណៈសម្បត្តិអាចទទួលបានសេវាកម្មអប់រំពិសេសទេ តើគេអាចមានសិទ្ធិទទួលបាន ឧបករណ៍បច្ចេកវិជ្ជាជំនួយតាមរយៈមណ្ឌលសិក្សាស្រុកដែរឬទេ?

កូនរបស់អ្នកអាចទទួលបានធានារ៉ាប់រងក្រោមឧបញ្ញត្តិប្រឆាំងនឹងការរើសអើងនៃក្រុមជនពិការអាមេរិកាំង (ADA, Americans with Disabilities Act) ឬវគ្គទី 504 នៃក្រុមស្តានីតិសម្បទា (Rehabilitation Act) ។ កូនរបស់អ្នកអាចទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយសម្រាប់ជាការជួយសម្រួលសមរម្យ ក្រោម ADA ឬជាផ្នែកមួយនៃការទទួលខុសត្រូវរបស់សាលា ដើម្បីផ្តល់ជូន FAPE និងមិនបាច់បង់ថ្លៃ ក្រោមវគ្គទី 504 ។ បើកូនរបស់អ្នកប្រើកៅអីកង់ គឺមានន័យថា កូនរបស់អ្នកអាចត្រូវការតុពិសេស ដែលអាចឲ្យគេអង្គុយរៀនបាន ។

### 15. តើកូនរបស់ខ្ញុំអាចទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយ ដើម្បីចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈដែរឬទេ?

អាចផ្តល់ជូនបាន ។ គ្រប់សិស្សដែលត្រូវទទួលការអប់រំពិសេសទាំងអស់ អាចទទួលបានសេវាកម្មអន្តរកាល ដែលមានរួមបញ្ចូលនូវសេវាកម្មបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ។ សេវាកម្មទាំងអស់នេះ អាចរួមបញ្ចូលនូវការបណ្តុះបណ្តាលជំនាញសំអាតថែទាំខ្លួន ជំនាញសង្គម និងអាកប្បកិរិយាកិច្ចការទូទៅនៅក្នុងថ្នាក់រៀន កន្លែងធ្វើការ និងនៅក្នុងសហគមន៍ ។ 34 C.F.R.វគ្គទី 300.43 ។ ឧបករណ៍ជំនួយបច្ចេកវិជ្ជាសាមញ្ញៗ ដើម្បីកែសម្រួលសេវាកម្មបណ្តុះបណ្តាល អាចរួមបញ្ចូលនូវតុដែលអាចឲ្យជនពិការអង្គុយបាន ម៉ាស៊ីនកុំព្យូទ័រដែលចេះនិយាយ និងសញ្ញាដែលបញ្ចេញជាសម្លេង ឬបញ្ចេញជាពន្លឺ ។ បើកូនអ្នកត្រូវការការកែសម្រួលអ្វីមួយ ការកែសម្រួលនោះត្រូវមានសរសេរចូលក្នុង IEP ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។